01054549

E329/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 14 / 01 / 2015
ម៉ោង (Time/Heure) : 14 : 15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥

ជូនចំពោះ៖ លោក ម៉ៅ សុភារម្យ
ប្រធានមន្ទីរឃុំឃាំងនៃ អ.វ.ត.ក

ពី៖ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន៖ លោក/លោកស្រីចៅក្រម មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ការិយាល័យរដ្ឋបាល អង្គភាពគាំពារសាក្សី និងអ្នកជំនាញ លោក **Claude Bouchard** មន្ត្រីសម្របសម្រួលមន្ទីរឃុំឃាំង

កម្មវត្ថុ៖ សំណើសុំសម្របសម្រួលលើការពិនិត្យ និងវាយតម្លៃរបស់អ្នកជំនាញដែលអង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យអនុវត្ត

១. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាសម្រេចចាត់តាំងអ្នកជំនាញពីររូប គឺ វេជ្ជបណ្ឌិត Chan Kin Ming និងវេជ្ជបណ្ឌិត ហួត លីនណា ដើម្បីពិនិត្យ និងវាយតម្លៃលើសម្បទារបស់ជនជាប់ចោទ នួន ជា និង ខៀវ សំផន ក្នុងការចូលរួមសវនាការ និងដើម្បីរៀបចំរបាយការណ៍ជាលាយលក្ខណ៍អក្សរលើប្រធានបទនេះជូនអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E329)។

២. ដើម្បីឲ្យអ្នកជំនាញអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យប្រធានមន្ទីរឃុំឃាំង សហការជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញសម្របសម្រួលលើការងាររបស់អ្នកជំនាញដោយអនុញ្ញាតឲ្យពួកគាត់ពិគ្រោះយោបល់ជាមួយនឹងជនជាប់ចោទ គ្រួសាររបស់ពួកគេរៀងៗខ្លួន និងបុគ្គលិកមន្ទីរឃុំឃាំង រួមទាំងគ្រូពេទ្យព្យាបាល និងអនុរក្សមន្ទីរឃុំឃាំងផងដែរ។